ព្រឹត្តប័ត្រ
ព័ត៌មាន
លេខ ០៨

# គម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅមូលដ្ឋានសហគមន៍(CDRR)

ADB - Grant 9178 - CAM

## *ពិធីប្រគល់គ្រឿងសង្ហារឹមការិយាល័យដល់មូលដ្ឋានសហគមន៍*

*ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០១៨*



## ពិធីប្រគល់គ្រឿងសង្ហារឹមការិយាល័យដល់មូលដ្ឋានសហគមន៍ទាំង ៦ ខេត្ត ១៨ស្រុក និង ៥៤ ឃុំសង្កាត់របស់គម្រោងដើម្បីប្រើប្រាស់ ។





*សកម្មភាពត្រួតពិនិត្យ សម្ភាររបស់ក្រុមការងារគម្រោង និងក្រុមហ៊ុនឯកជនពេលបានដល់គោលដៅ ។*



*សកម្មភាពក្រុមការងារគម្រោង និងក្រុមហ៊ុនឯកជនជួយរៀបចំ និងតុបតែងការិយាល័យមុខដាក់គ្រឿងសង្ហារឹមថ្មីចូល។*

ដោយសារមានការសម្របសម្រួលពីថ្នាក់ដឹកនាំ ជាពិសេសពីសំណាក់ **ឯកឧត្តម ឡាំ ហេងហួត** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.គ.ម. និងជានាយកគម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយកម្រិតមូលដ្ឋានសហគមន៍ (CDRR) កាលពីថ្ងៃទី ១៦-២០ ខែកក្កដា ឆ្នាំ ២០១៨ មានការរៀបចំប្រគល់សម្ភារគ្រឿងសង្ហារឹមមានដូចជា តុដែក ទូដែកបីថ្នាក់ និងកៅអីឱ្យទៅមូលដ្ឋានសហគមន៍ទាំង៦ខេត្ត ១៨ ស្រុក និង ៥៤ ឃុំសង្កាត់ របស់គោលដៅគម្រោងដើម្បីយកប្រើប្រាស់ជាប្រយោជន៍សម្រាប់កាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅមូលដ្ឋានសហគមន៍របស់គាត់។ ក្នុងនោះមួយស្រុកៗទទួលបានតុដែកមួយ ទូដែកបីថ្នាក់មួយ និងកៅអីមួយ ចំណែកឯឃុំសង្កាត់វិញក៏ទទួលបានដូចស្រុកដែរក្នុងនោះមួយឃុំៗទទួលបានតុដែកមួយ ទូដែកបីថ្នាក់មួយ និងកៅអីមួយ។

លោក **ផៃ សុភាព** ប្រធានគ្រប់គ្រងគម្រោង និងជាតំណាងរបស់ ឯកឧត្តម **ឡាំ ហេងហួត** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.គ.ម. និងជានាយកគម្រោងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយកម្រិតមូលដ្ឋានសហគមន៍នៅកម្ពុជា (CDRR) បានមានប្រសាសន៍ថា "*នេះជាលើទីបីហើយដែលគម្រោងបានចែកសម្ភារទៅឲ្យមូលដ្ឋានសហគមន៍ចំនួន ១៨ ស្រុក និង៥៤ ឃុំ/សង្កាត់ទាំងប្រាំមួយខេត្ត បន្ទាប់ពីការប្រគល់សម្ភារការិយាល័យដូចជា៖ (១) ក្រដាស A4 ចំនួន ៦០រ៉េម (២) ក្រដាសបិទចំណាំចំនួន ២៤ដុំ (៣) ស្រោមសំបុត្រចំនួន ១០កញ្ចប់ដែលក្នុងមួយកញ្ចប់មានចំនួន ៥០ស្រោមសបុត្រ (៤) ស៊ីឌីផ្លាស់ស្ទិចចំនួន ១៦កញ្ចប់ដែលក្នុងមួយកញ្ចប់មានចំនួន ១០ស៊ីឌី (៥) ស៊ីមីក្រដាសចំនួន ៤០០ដុំ (៦) ហ្វឺតគូសចំណាំចំនួន ១០ដុំ (៧) ទឹកលុបចំនួន ១២ដើម (៨) ក្រណាត់ចំនួន ១២ដុំ (៩) ការស្ទួតចំនួន ៨ដើម (១០) ប៊ិចចំនួន ៤ប្រអប់ក្នុងមួយប្រអប់មានចំនួន ១២ដើម (១១) សៀវភៅកត់ត្រាចំនួន ២០ដុំ (១២) ឃ្នៀបចំនួន ២០កញ្ចប់ (១៣) ឃ្នៀបធំចំនួន ១២កញ្ចប់ (១៤) គ្រាប់កឹបចំនួន ២០កញ្ចប់ និង(១៥) ទឹកថ្នាំព្រីនទ័រចំនួន ១ដុំ ហើយនងកុំព្យូទ័រយួរដៃ ម៉ាស៊ីនព្រីនទ័រ និងបន្ទះថាមពលពន្លឺព្រះអាទិត្យ ។ លោកក៏បានបន្ថែមទៀតថាទាំងអស់នេះសុទ្ធតែបានមកពីការខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំទាំងអស់របស់គម្រោង ជាពិសេសគឺថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ទាំងអស់របស់លេខាធិការដ្ឋាន គ.ជ.គ.ម. លោកក៏បានកោតសរសើរផងដែរចំពោះលេខាធិការដ្ឋាន គ.គ.ម.ស. និងលេខាធិការដ្ឋាន គ.គ.ម.ឃ. ដែលបានជួយគាំទ្រគម្រោងយ៉ាងខ្លាំង និងជោគជ័យរហូតមកដល់ពេលនេះ ហើយសម្ភារការិយាល័យ និងទឹកថ្នាំព្រីនទ័រទាំងអស់នេះគឺជាតំរូវការពិតៗដើម្បីចូលរួមចំណែកកាត់បន្ថយហានិភ័យគ្រោះមហន្តរាយកម្រិតមូលដ្ឋានសហ*

ក្រោយពេលបញ្ចប់ការសំណេះសំណាល និងថតរូបអនុស្សាវរីយ៍ អ្នកមីង លោកពូ និងបងប្អូនដែរជាសមាជិកលេខាធិការដ្ឋាន គ.គ.ម.ស. និងលេខាធិការដ្ឋាន គ.គ.ម.ឃ. មានចិត្តរីករាយខ្លាំងណាស់ ដោយម្នាក់ៗប្តេជ្ញាចិត្តថានឹងប្រើប្រាស់សម្ភារទាំងអស់នេះអោយចំទិសដៅដើម្បីជាប្រយោជន៍ក្នុងការជួយកាត់បន្ថយហានិភ័យគ្រោះមហន្តរាយកម្រិតមូលដ្ឋានសហគមន៍របស់គាត់ ៕✍



*លោក អ៊ំ មេឃុំ និងជាក្រុមការងារលេខាធិការដ្ឋាន គ.គ.ម.ឃ. បានអង្គុយសាកល្បងនៅលើតុថ្មី ដោយក្តីរីករាយ និងភាពជឿរជាក់ទៅលើគម្រោង និងការដឹកនាំដ៏វៃឆ្លាតរបស់ប្រមុខរដ្ឋាភិបាល ។*